Cercle Éclipse and Hach KimSoeun shared មាតុភូមិ ប្រឆាំងដេីម្បីរស់ ខ្មែរ's video.

# មាតុភូមិ ប្រឆាំងដើម្បីរស់ ខ្មែរ

ឮហើយណាបងប្អូនទាំងអស់គ្នា ភាសាដែលនរោត្តម សុីហនុគាត់និយាយនោះ! អញ្ចឹងខ្ញុំសូមបងប្អូនខ្មែរទាំងអស់លើពិភពលោក មិនថាបងប្អូននិន្នាការបក្សណាទេ វាជាសិទ្ធិរបស់បងប្អូន ក៏ប៉ុន្តែគ្រាន់តែចង់ឲ្យបងប្អូនពិចារណារទាំងអស់គ្នា ងាកទៅក្រោយបន្តិចអំពីប្រវត្តិសាស្ត្រខ្មែរ។ ធម្មតាបារាំងដែលមកធ្វើអាណានិគមលើប្រទេសខ្មែរ លាវ យួន គឺបារាំងវាស្គាល់ព្រំដែននៃទឹកដីប្រទេសនិមួយៗច្បាស់លាស់ណាស់មុននឹងកំណត់រដ្ឋបាលនៃការយកពន្ធដាផ្សេងទៅតាមតំបន់នៃប្រទេសទាំងបី(កម្ពុជា-លាវ-យួន)។

ដូច្នេះមុនពេលដែលបារាំងដកអំណាចអាណានិគមចេញពីឥណ្ឌូចិន-បារាំងក៏បានកាត់ដីខ្មែរភាគខាងត្បូងឈៀងខាងកើតនៃប្រទេសកម្ពុជា ឲ្យទៅយួន(កម្ពុជាក្រោម)រួចជាស្រេចបាត់ហើយ ទើបដកអំណាចជាក្រោយ។

អញ្ចឹងខ្ញុំដូចជាឆ្ងល់ ហើយយើងនឹងសាកល្បងធ្វើការពិចារណារទាំងអស់គ្នាឲ្យយល់ហេតុផល ។ បារាំងកាត់ដីខ្មែរឲ្យយួនក្នុងឆ្នាំ១៩៤៩ដោយស្ងាត់ៗ មិនមានអាជ្ញាធរខ្មែរ ឬស្តេចខ្មែរដឹងឮនឹងចូលរួម ! ហើយច្បាប់អន្តរជាតិបានកើតឡើងជាធរមានក្នុងឆ្នាំ១៩៤៥ក្រោយពីសង្គ្រាមលោកលើកទី(២)ត្រូវបានបញ្ចប់ គឺមុនបារាំងកាត់ដីឲ្យយួន៤ឆ្នាំ។ តើយើងគួរឆ្ងល់ទេ? ហេតុអីបានជាអាជ្ញាធរខ្មែរឬស្តេចខ្មែរមិនព្រមប្តឹងទៅអង្គការសហប្រជាជាតិ បើសិនជាខ្លួនមិនបានរួមគំនិតកាត់ដីខ្មែរជាមួយបារាំងឲ្យទៅយួនទេ ក្រោយពីថាបានឯករាជ្យក្នុងឆ្នាំ១៩៥៣នោះ?សួរថាតើហេតុអី? នេះជាចំណោទមួយដែលយើងត្រូវគិតអំពីរឿងនេះ។ រឿងសំខាន់មួយទៀតដែលកូនខ្មែរទាំងអស់គ្នាលើពិភពលោកត្រូវពិចារណានិងស្រាវជ្រាវឲ្យច្បាស់លាស់និងសុីជំរៅឲ្យមែនទែន គឺក្រោយពីបានដីខ្មែរក្នុងឆ្នាំ១៩៤៩នោះភ្លាម យួនបានបង្កើតជាប្រទេសមួយគឺវៀតណាមខាងត្បូង ក្នុងពេលនោះប្រទេសយួនបានពីរហើយគឺ( យួនខាងជើង+យួនខាងត្បូង)ដែលជាទឹកដីខ្មែរសុទ្ធសាធ។ បន្ទាប់មកលទ្ធិកុម្មុយនីស្តរបស់មហាអំណាចធំៗពិភពលោក សូវៀត និង ចិន បានរីកដុះដាលពេញទ្វិបអាសុីភាគអគ្នេយ៍ ដោយជ្រាបពេញប្រទេសយួនខាងជើង ធ្វើឲ្យមហាអំណាចសេរីមានការបារម្ភជាខ្លាំងខ្លាចកុម្មុយនីស្តរីដុះដាលពេញពិភពលោក ទើបសហរដ្ឋអាមេរិកបញ្ជូនទ័ពទៅកាន់វៀតណាមខាងត្បូង(កម្ពុជាក្រោម)ក្នុងគោលបំណងការពាររារាំងមិនឲ្យរបបកុម្មុយនីស្តជ្រៀតចូលដល់វៀតណាមខាងត្បូងទៀត។ប៉ុន្តែជាអកុសលណាស់! ស្តេចរបស់ខ្មែរយើង មិនត្រឹមតែមិនបានប្តឹងអង្គការសហប្រជាជាតិដើម្បីទាមទារដីពីយួនមកវិញ ដែលបារាំងបានកាត់អោយប៉ុណ្ណោះទេ ថែមទាំងទៅជួយពួកយួនកុម្មុយនីស្តខាងជើង ដើម្បីវាយយកទឹកដីយួនខាងត្បូង ដែលជាដីរបស់ខ្មែរឯងទៅវិញទៀត! តែធ្វើនេះហាក់បីដូចខ្លាចអាមេរិកនិងក្រុមធៀវគីប្រគល់ដីយួនខាងត្បូងឲ្យខ្មែរវិញអញ្ចឹង! ខ្ញុំមិនមែនចេះតែនិយាយមុសារនោះទេ តែបងប្អូនអាចស្គាល់សម្លេងគាត់ហើយ។

ដូច្នេះសូមកូនខ្មែរទាំងអស់នៅលើពិភពលោកយើងសាកគិតទាំងអស់គ្នាមើល! បើនរោត្តមសុីហនុ មិនបានចុះហត្ថលេខាកាត់ដីខ្មែរជាមួយបារាំងឲ្យយួនទេនោះ ហេតុអីបានមិនព្រមប្តឹងទៅអន្តរជាតិយកដីមកវិញ បើមិនពាក់ព័ន្ធទេ ហេតុអីក៏ជួយយកដីខ្មែរ(កម្ពុជាក្រោម)លើកឲ្យយួនខាងជើងទៅវិញ! សូមលោកអ្នកមេត្តាពិចាណាចុះ!!!